**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**អគ្គលេខាធិការដ្ឋាន**
លេខ: ០៩៥/១៨ ប.ន អ.ជ.ប.គ.ញ

ថ្ងៃអង្គារ ១០កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកក្កដា និងទិសដៅការងារ ខែសីហា ឆ្នាំ២០១៨

(២៦/០៦/២០១៨ - ២៥/០៧/២០១៨)

ក្នុងខែកក្កដានេះ ជាខែដែលមានព្រឹត្តិការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ទន្ទឹមគ្នានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតែខិតខំយកចិត្តទុកដាក់អនុវត្តនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ របស់រាជរដ្ឋាភិបាល រយៈពេល១ឆ្នាំ ដែលបានដាក់ចេញដើម្បីចូលរួមពង្រឹង និងរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ក្នុងគោលបំណងធានាឱ្យបាននូវភាពកក់ក្តៅជូនប្រជាពលរដ្ឋនាំគ្នាទៅបោះឆ្នោត និងទប់ស្កាត់រាល់សកម្មភាពអសកម្មនានា ដោយប្រមូលផ្តុំសមាសភាពពីគ្រប់មូលដ្ឋានអនុវត្តយ៉ាងសកម្មក្លៀវក្លាបន្ថែមពីលើការអនុវត្តផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ តាមរយៈ ការអនុវត្តផែនការយុទ្ធនាការ និងផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក៏ដូចជាផែនការសកម្មភាពអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែមិថុនាកន្លងទៅ យើងបានកត់សម្គាល់ពីសភាពការណ៍គ្រឿងញៀន និងអនុវត្តការងារនៅក្នុងខែកក្កដានេះ សម្រេចបានលទ្ធផលដូចតទៅ ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែកក្កដានេះ ការចោរចរដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ពីតំបន់ត្រីកោណមាស ឆ្លងកាត់ប្រទេសឡាវចូលមកកម្ពុជាតាមបណ្តាច្រកនៃខេត្តភាគឦសានប្រទេស នៅតែបន្តមានសកម្មភាពគួរឱ្យព្រួយបារម្ភ ។ ជាក់ស្តែង៖

- ការិយាល័យទំនាក់ទំនងព្រំដែនត្រពាំងក្រៀល (BLO) បង្ក្រាប ១ ករណី (ឃាត់ខ្លួន ៣នាក់) ចាប់យកមេតំហ្វេតាមីន (ICE) ជិត ១២០ គ.ក្រ និងបន្តសហការជាមួយមន្ទីរប្រឆាំងគ្រឿងញៀនតាមចាប់ខ្សែរយៈនៅភ្នំពេញ ៣ នាក់ និងចាប់យកមេតំហ្វេតាមីន (ICE), កេតាមីន សរុបប្រមាណជិត ២៧ គ.ក្រ និងប្រេងម្រះព្រៅភ្នំប្រមាណជាង ៦៣២ គ.ក្រ ។

- កម្លាំងនៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង បង្ក្រាប ១ ករណី ឃាត់ខ្លួនជនជាតិឡាវចំនួន ១ នាក់ ចាប់យកមេតំហ្វេតាមីន (ICE) ជាង ២ គ.ក្រ និងសហការជាមួយកម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន បង្ក្រាប ១ ករណី ឃាត់ខ្លួនជនជាតិឡាវចំនួន ១ នាក់ និងវត្ថុតាងគ្រឿងញៀនមេតំហ្វេតាមីន (ICE) ជាង ២ គ.ក្រ ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

**ដោយឡែក តាមប៉ុស្តិ៍ប្រៃសណីយ៍ ៖**

– កម្លាំងចម្រុះស៊ើបអង្កេតបទល្មើសឆ្លងកាត់ព្រំដែន បង្ក្រាបករណីដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ ២ករណី ឃាត់ខ្លួនជនជាតិវៀតណាម ២ នាក់ និងវត្ថុតាងមេតំហ្វេតាមីន (ICE) និងអ៊ិចស្តាស៊ី សរុបជាង១៦ គ.ក្រ ។

– កម្លាំងសន្តិសុខផ្ទៃក្នុងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយកម្លាំងចម្រុះស៊ើបអង្កេតបទល្មើសឆ្លងកាត់ព្រំដែន បង្ក្រាប ៦ ករណី ឃាត់ខ្លួនជនជាតិចិនចំនួន ៥ នាក់ និងវត្ថុតាងមេតំហ្វេតាមីន (ICE) និងអ៊ិចស្តាស៊ី និងកេតាមីន សរុបប្រមាណជិត ៥២ គ.ក្រ ។

## II. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ប្រធាន អ.ជ.ប.គ.ញ. បានបន្តដឹកនាំ និងណែនាំលើការងារសំខាន់ៗ ជាពិសេសការងារពាក់ព័ន្ធនឹងការអនុវត្តផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងការចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ ដូចខាងក្រោម ៖

**១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវបន្តជំរុញការអនុវត្តវិធានការផ្សព្វផ្សាយអប់រំដល់សិស្ស-និស្សិត កម្មករ-កម្មការនី ពលករ ជនចំណាកស្រុក តាមគ្រប់រូបភាព និងបន្តការរៀបចំវេទិកាតុមូល វេទិកាសាធារណៈ វេទិកាជួបជាមួយវិស័យឯកជន ព្រមទាំងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** ត្រូវបន្តពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរដ្ឋនិងឯកជនឱ្យមាននិរន្តរភាព ដើម្បី ទទួលជនរងគ្រោះដែលអង្គភាពអនុវត្តន៍ច្បាប់ ស្ថាប័នតុលាការបញ្ជូនទៅទទួលសេវាព្យាបាល, ត្រូវពង្រឹងពង្រីក សេវាព្យាបាលដោយផ្អែកលើសហគមន៍តាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកបន្ថែមទៀត ។ ជាមួយនេះ ត្រូវពិនិត្យស្នើសុំមូលនិធិសមធម៌ជូនដល់អ្នកញៀនគ្រឿងញៀន ដែលទៅទទួលសេវាពិនិត្យ និងព្យាបាលភាពញៀនគ្រឿងញៀន ដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ព្រមទាំងពង្រឹងសេវាគាំទ្រផ្សេងៗទៀត សំដៅ លើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍ ដើម្បីកាត់បន្ថយការលាប់ទៅប្រើគ្រឿងញៀនឡើងវិញ និងបន្តដំណើរការសាងសង់មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅភូមិឫស្សី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឲ្យបានឆាប់រហ័ស ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមរយៈការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀន និងសារធាតុគីមីផ្សំ តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ **(CBT)**, តាមប្រព័ន្ធអេឡិចត្រូនិក (e-Learning), និងការបណ្តុះបណ្តាលជំនាញផ្សេងៗទៀតដល់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន **(BLO)**, មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងក្រុមជនបង្គោលនៃកងយោធពលខេមរភូមិន្ទ ។ ទន្ទឹមនេះ ត្រូវពង្រឹងនីតិវិធីក្នុងការជម្រះក្តីពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន និងនីតិវិធីនៃការរឹបអូសទ្រព្យសម្បត្តិឱ្យបានឆាប់ ដើម្បីគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ បន្តនីតិវិធីហិរញ្ញវត្ថុឱ្យទាន់ពេលវេលា ចៀសវាងការខូចខាត ធ្លាក់ចុះតម្លៃ ឬឈានដល់បាត់បង់តម្លៃសេដ្ឋកិច្ចទាំងស្រុងនៃទ្រព្យសម្បត្តិទាំងនោះ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** បន្តជំរុញការងាររបស់ក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំឱ្យបានទៀងទាត់ និងការងាររបស់ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។ ជាមួយនេះ ត្រូវសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម បន្តការរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិ ស្តីពីការបិទស្លាកសញ្ញាការទុកដាក់ការវេចខ្ចប់នូវសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម បន្តការចងក្រងព័ត៌មានពាក់ព័ន្ធ និងសារ

ជាតុញៀនថ្មីដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** បន្តអនុវត្តនូវរាល់កិច្ចការ ដែលបានព្រមព្រៀងគ្នាកន្លងមកជាមួយភាគី ថៃ ឡាវ និង វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនព្រមទាំងការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់ប្រទេសកម្ពុជា ថៃ និងឡាវ ជាពិសេសអនុវត្តយន្តការភូមិ ស គ្មានគ្រឿងញៀន នៅតាមព្រំដែនដែលភាគី កម្ពុជា ឡាវ ថៃ បានឯកភាពគ្នាកន្លងមករួមទាំងកិច្ចអន្តរាគមន៍នានាដែលមានលក្ខណៈពហុវិស័យ ក្នុងការពង្រឹងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន **(BLO)** តាមបណ្តោយព្រំដែន កម្ពុជា-ឡាវ, កម្ពុជា-ថៃ និង កម្ពុជា-វៀតណាម ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា ៖** បន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី អង្គការ UNODC បណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជាមួយនេះ ត្រូវធ្វើការណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅគ្រប់ឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាព សម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

ក្រៅពីការងារដឹកនាំ និងណែនាំជាគោលការណ៍សំខាន់ៗខាងលើ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានជួបសំណេះសំណាលនិងបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋនៅស្រុកអូរជ្រៅ ស្រុកស្វាយចេក ស្រុកមង្គលបុរី ក្រុងសិរីសោភ័ណ និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ចំនួន **១១៤.៨០៧ នាក់** ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឆ្លើយតបទៅនឹងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ និងទិសដៅការងារដែលបានដាក់ចេញកាលពីខែមិថុនា ឆ្នាំ២០១៨ និងតាមការណែនាំរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

#### ១.១. ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

- សហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី. អញ្ជើញតំណាងស្នងការនគរបាលខេត្តកំពង់ស្ពឺ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងតំណាងស្នងការនគរបាលរាជធានីភ្នំពេញ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច " ក្រោមប្រធានបទការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ "
- សហការជាមួយស្ថានីយវិទ្យុFM ជាតិ ៩៦ Mhz បានអញ្ជើញអធិការដ្ឋាននគរបាលខណ្ឌចំការមន អធិការដ្ឋាននគរបាលខណ្ឌទួលគោក អធិការដ្ឋាននគរបាលខណ្ឌមានជ័យ និងអធិការដ្ឋាននគរបាលខណ្ឌសែនសុខ ចូលរួមជាវាគ្មិនផ្តល់បទសម្ភាសន៍ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃការប្រើប្រាស់និងដំណោះស្រាយបញ្ហាគ្រឿងញៀន
- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែកក្កដា ឆ្នាំ២០១៨ មានការចូលអានចំនួន **៤៨.២៦៤ ដង**

- ផ្សព្វផ្សាយឃ្លីបវីដេអូខ្លីស្តីពីបញ្ហាគ្រឿងញៀន និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក តាមបណ្តាញទំនាក់ទំនងសង្គម Page Facebook របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**១.២. ការងារអប់រំតាមសហគមន៍**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន មានមហាជនទៅទទួលសារសារអប់រំចំនួន **១៧៥.៥៩៧** នាក់ ។

ក្នុងនោះ ការងារដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានសហការអនុវត្តមាន ៖

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្រ្តីទៅចូលរួមជាមួយគ្រូបង្គោលធ្វើបទឧទ្ទេសនាមពីបញ្ហាគ្រឿងញៀន ជូនដល់និស្សិតសិក្សាថ្នាក់មូលដ្ឋាននៃសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ នៅក្នុងសិក្ខាសាលាស្តីពីផលប៉ះពាល់នៃការជួញដូរ និង ប្រើប្រាស់គ្រឿងញៀន កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ នៅក្នុងសាកលវិទ្យាល័យស្រុកកំចាយមារ ខេត្តព្រៃវែង ដែលមានអ្នកចូលរួម ៣០០ នាក់
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្ត្រី ចូលរួមធ្វើបទបង្ហាញក្នុងកម្មវិធីផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន កម្មវិធីជួបជាមួយវិស័យឯកជន ដែលរៀបចំដោយក្រសួងទេសចរណ៍ កាលថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ នៅខេត្តតាកែវ ដែលមានអ្នកចូលរួម១០០នាក់
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចាត់បញ្ជូនមន្ត្រី ២រូប ទៅចូលរួមធ្វើបទបង្ហាញស្តីពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន ក្នុងពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលរៀបចំដោយអង្គការអភិវឌ្ឍន៍សមត្ថភាពសមាគម កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ នៅសាលាបឋមសិក្សាក្តីតាកុយ សង្កាត់ វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
- អគ្គលេខាធិការ អ.ជ.ប.គ.ញ. ចូលរួមធ្វើបទឧទ្ទេសនាមក្នុងសិក្ខាសាលា ស្តីពីសភាពការណ៍ និងផលប៉ះពាល់នៃគ្រឿងញៀន នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ មានអ្នកចូលរួម ១៤០នាក់
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចាត់បញ្ជូនមន្ត្រី ៤រូប ទៅចូលរួមធ្វើបទបង្ហាញស្តីពីបញ្ហាគ្រឿងញៀន នៅក្នុងពិធីផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្រុងបាត់ដំបង ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា និងគណៈ កម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបាត់ដំបង កាលពីថ្ងៃទី១៧-១៨ ខែកក្កដា ឆ្នាំ២០១៨
- អគ្គលេខាធិការ អគ្គលេខាធិការរង អ.ជ.ប.គ.ញ., បានចូលរួមជាអធិបតីក្នុងទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ តាមបណ្តាខេត្តគោលដៅចំនួន ៩ ខេត្តគឺ៖
  - ខេត្តបន្ទាយមានជ័យ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ មានមហាជនចូលរួម ១.៣៧១ នាក់
  - ខេត្តបាត់ដំបង ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ មានមហាជនចូលរួម ២.០០០ នាក់
  - ខេត្តស្វាយរៀង ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ មានមហាជនចូលរួម ៣.៤០០ នាក់
  - ខេត្តកោះកុង ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ មានមហាជនចូលរួម ៤.៣០០ នាក់
  - ខេត្តសៀមរាប ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ មានមហាជនចូលរួម ៤០០ នាក់
  - ខេត្តព្រះសីហនុ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ មានមហាជនចូលរួម ៤៣៨ នាក់
  - ខេត្តស្ទឹងត្រែង ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ មានមហាជនចូលរួម ១.៥១២ នាក់
  - នៅខេត្តត្បូងឃ្មុំ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ មានមហាជនចូលរួម ១.៤០០ នាក់

- នៅតាកែវ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ មានមហាជនចូលរួម ៤១៤ នាក់

– ក្រសួងសាធារណការនិងដឹកជញ្ជូន បានស្នើក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ឱ្យណែនាំអ្នកបើកបរ កុំឱ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងស្នើឱ្យមានការបិទខិត្តប័ណ្ណផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន ខុសច្បាប់ នៅតាមរថយន្ត ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

– ក្រសួងសុខាភិបាល បន្តផ្តល់សេវាព្យាបាលដោយឱសថជំនួសមេតាដូន ដល់អ្នកញៀនហេរ៉ូអ៊ីន (ពពួកអាភៀន)

– បានបន្តការគាំទ្រចំពោះអង្គការដៃគូ ដែលបាននិងកំពុងអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដើម្បីកាត់បន្ថយការឆ្លងមេរោគអេសដ៍ និងរោគឆ្លងតាមឈាមផ្សេងៗទៀត។

### ២.២. ការព្យាបាល និងស្តារនីតិសម្បទា

– បានជំរុញឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ពង្រឹងឬបង្កើតគណៈកម្មការសម្របសម្រួលការព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមឃុំ-សង្កាត់ ដើម្បីជំរុញឱ្យអ្នកប្រើប្រាស់និងអ្នកញៀនគ្រឿងញៀនទៅទទួលយកការព្យាបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្ត នៅតាមសហគមន៍

– អគ្គលេខាធិការ អ.ជ.ប.គ.ញ. បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកឧក្រិដ្ឋកម្ម និងគ្រឿងញៀន (UNODC) សម្រាប់ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

– អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្ត្រី ២រូប ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតបទល្មើសតាមប្រព័ន្ធអនឡាញសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ដែលរៀបចំដោយការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ (UNODC) កាលពីថ្ងៃទី២៧-៣០ ខែមិថុនា ឆ្នាំ២០១៨ នៅខេត្តសៀមរាប មានអ្នកចូលរួម ២០រូប

– អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្ត្រី ១រូប ចូលរួមវគ្គបណ្តុះបណ្តាលអាស៊ាន បូក៣ ស្តីពីគម្រោងនៃការបង្ក្រាបសារធាតុគីមីផ្សំ និងសារធាតុញៀនផ្សេងៗ សម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ លើកទី៣ ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ONCB ពីថ្ងៃទី០២-១៧ ខែកក្កដា ឆ្នាំ២០១៨ នៅប្រទេសថៃ

– អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្ត្រី ១៥ រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរៀបចំដោយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនចិន ពីថ្ងៃទី២៣ ខែមិថុនា ដល់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៨ នៅទីក្រុងគុនមិញ សាធារណរដ្ឋប្រជាមានិតចិន ។

## ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

ក្នុងខែកក្កដានេះ កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនមានដូចខាងក្រោម ៖

– **បទល្មើសបង្ក្រាបបាន សរុប ៦០០ ករណី** (រួមទាំងបទល្មើសប្រើប្រាស់)

គ្មានការកើនឡើង បើប្រៀបធៀបខែមិថុនា មាន ៦០០ករណី ។

– **ជនសង្ស័យដែលឃាត់ខ្លួន សរុប ១.២០៣ នាក់ ស្រី៩៩ នាក់** (រួមទាំងជនប្រើប្រាស់)

មានការកើនឡើង ៥៩នាក់ ស្មើនឹង ៥.១៥% បើប្រៀបធៀបខែមិថុនាមាន ១.១៤៤ នាក់ ។

ក្នុងនោះមាន ៧ សញ្ជាតិគឺ : ខ្មែរ ១.១៧៩នាក់ (ស្រី ៩៧នាក់) ,វៀតណាម ១៥ នាក់ (ស្រី ២ នាក់), ឡាវ ១នាក់, ចិន ៥នាក់, តៃវ៉ាន់ ១នាក់, នីហ្សេរីយ៉ា ១នាក់, កូរ៉េ ១នាក់ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

– **វត្ថុតាងគ្រឿងញៀន ចាប់យកសរុប ២៥៩$^{គ.ក្រ}$ ៤២៥$^{ក្រាម}$ ៨៨០$^{មីលីក្រាម}$**

**រួមមាន** មេតំហ្វេតាមីនក្រាមម្សៅ(ICE) ១៦៥$^{គ.ក្រ}$ ៨៧៤$^{ក្រាម}$ ១២០$^{មីលីក្រាម}$, មេតំហ្វេតាមីនគ្រាប់ (WY) ៦១៤$^{ក្រាម}$ ១៥០$^{មីលីក្រាម}$, អ៊ិចស្តាស៊ី(MDMA) ៦៤$^{គ.ក្រ}$ ១៩៣$^{ក្រាម}$, ៤១០$^{មីលីក្រាម}$, ហេរ៉ូអ៊ីន ៧០១$^{ក្រាម}$ ៧៤០$^{មីលីក្រាម}$, កេតាមីន ២៧$^{គ.ក្រ}$ ៨៦១$^{ក្រាម}$ ២៦០$^{មីលីក្រាម}$, កញ្ឆាក្រៀម **១៨០**$^{ក្រាម}$ ២០០$^{មីលីក្រាម}$, ដើមកញ្ឆា ៧.៣៨៤$^{ក្រាម}$ ។

– **ទ្រព្យសម្បត្តិសំខាន់ៗ** ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនមាន រថយន្ត ៨ គ្រឿង ម៉ូតូ ១៧០ គ្រឿង, ប្រាក់កម្ពុជា ២.៥៨៣.៨០០ រៀល, ប្រាក់ថៃ ១៨០ បាត, ប្រាក់អាមេរិក ២.៦៧៦ ដុល្លារ ។

**ក្នុងចំនួនបទល្មើសគ្រឿងញៀនខាងលើ ៖**

➢ បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចនគរបាល ៤៩២ករណី** ឃាត់ខ្លួនជនសង្ស័យ **៩៦១**នាក់ (ស្រី ៨៣នាក់)

➢ បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថ ១០៨ករណី** ឃាត់ខ្លួនជនសង្ស័យ **២៤២នាក់** (ស្រី ១៦នាក់)

– **ជនសង្ស័យចាប់តាមដីកា** មាន ១៨ ដីកា ចាប់បានជនសង្ស័យ ១៨ នាក់ (ប្រុស) ។

## ៣.៣. លទ្ធផលកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

– សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសលវិច័យ ក្នុងខែកក្កដា ឆ្នាំ២០១៨ មាន **៤៤៦ ករណី** ស្មើនឹង **៤៧០សំណាក** ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន** មាន = **៤៧០សំណាក** (៩៧,២១%) គឺ :
  - ➢ មេតំហ្វេតាមីនគ្រាប់ (WY) ២៣សំណាក = ៤,៨៩%
  - ➢ មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៤២៨សំណាក = ៩១,០៦%
  - ➢ កេតាមីន ០១សំណាក = ០,២១%
  - ➢ ហេរ៉ូអ៊ីន ០២សំណាក = ០,៤២%
  - ➢ អ៊ិចស្តាស៊ី(MDMA) ០៣សំណាក = ០,៦៣%

• **សំណាកអរិជ្ជមានសារធាតុញៀន = ១៣សំណាក** (២,៧៦%) ។

– បានផ្តល់តេស្តរកសារធាតុញៀនមេតំហ្វេតាមីនក្រាមម្សៅ(ICE)ក្នុងទឹកនោម ៣.៥៣០ តេស្ត, តេស្តរកសារធាតុញៀនអ៊ិចស្តាស៊ី(MDMA)ក្នុងទឹកនោម ១៥០តេស្ត, ម៉ាគ្វីតេស្ត ២២០ តេស្ត, កូកាអ៊ីនតេស្ត២៥ តេស្ត, កេតាមីនតេស្ត ៥០ តេស្ត, ហេរ៉ូអ៊ីនតេស្ត ២៥ តេស្ត

– បានផ្តល់ស្រោមវេចខ្ចប់សំណាកសង្ស័យជាគ្រឿងញៀន ១០០ សន្លឹក ដល់អង្គភាពចំនួន ១០ រួមមាន : ស្នងការដ្ឋាននគរបាលពោធិ៍សាត់, កំពង់ឆ្នាំង, កំពង់ធំ, កោះកុង, ស្វាយរៀង, សៀមរាប, សាលាដំបូងខេត្តត្បូងឃ្មុំ, កងរាជអាវុធហត្ថលើផ្ទៃប្រទេស, កងរាជអាវុធហត្ថខេត្តកណ្តាល, កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំក្នុងតារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក្នុងខែកក្កដា ឆ្នាំ២០១៨ នេះ សរុបចំនួន **៧៧៩.៩០០** គ.ក្រ ក្នុងនោះ ៖

• ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានផ្តល់អាជ្ញាប័ណ្ណ និងលិខិតបញ្ជាក់មុខសញ្ញាស្តង់ដាប្រើប្រាស់សារធាតុគីមី ចំនួន ៧៣៩.៩០០ គ.ក្រ ។

• ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ផ្តល់អាជ្ញាប័ណ្ណ ចំនួន ៤០.០០០ គ.ក្រ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្ត្រី ១រូប ចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការប្រឆាំងបទល្មើសគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនដោយមានការចាត់តាំង (CTOC) ដែលរៀបចំដោយអង្គការសត្វព្រៃអាស៊ី ពីថ្ងៃទី២៥ ខែមិថុនា ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨ នៅប្រទេសថៃ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

– អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្ត្រី ៣រូប ចូលរួមសិក្ខាសាលាអាស៊ានស្តីពីកិច្ចប្រតិបត្តិការបណ្តាញឃ្លាំមើលគ្រឿងញៀនលើទី៦ ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ONCB ពីថ្ងៃទី០៩-១៣ ខែកក្កដា ឆ្នាំ២០១៨ នៅប្រទេសថៃ

– ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានសម្របសម្រួលជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្នើឱ្យមានការចាត់តំណាងមន្ត្រីស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំការប្រទេសប៊ែលហ្ស៊ិក ទៅចូលរួមកិច្ចប្រជុំក្រុមជំនាញEGM លើកទី៣ ស្តីពីការអភិវឌ្ឍដោយជម្រើសផ្សេងៗក្រៅពីការដាំដំណាំគ្រឿងញៀននាពេលអនាគត ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ស្ថាប័នត្រួតពិនិត្យគ្រឿងញៀនអាល្លឺម៉ង់ និងអង្គការ UNODC កាលពីថ្ងៃទី ២៣-២៦ ខែកក្កដា ឆ្នាំ២០១៨ នៅក្រុងវីយែន ប្រទេសអូទ្រីស ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

– បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីរៀបចំនីតិវិធីដាក់បញ្ចូលស្លឹករុក្ខជាតិខាត់ (KHAT) ទៅក្នុងតារាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

– បន្តជំរុញការអនុវត្តផែនការភូមិ ស គ្មានគ្រឿងញៀន នៅតាមបណ្តោយព្រំដែនកម្ពុជា ថៃ ឡាវ

– បាននិងកំពុងរៀបចំខ្លឹមសារនៃសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

– បាននិងកំពុងរៀបចំផែនការជាតិ ៥ ឆ្នាំ (២០១៩-២០២៣) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែសីហា ឆ្នាំ២០១៨

ដើម្បីអនុវត្តបន្តឱ្យមានប្រសិទ្ធភាព នូវផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៨ ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ (ឆ្នាំ២០១៨) អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បាន បានដាក់ចេញនូវផែនការសកម្មភាពអនុវត្តទិសដៅការងារ សម្រាប់**ខែសីហា ឆ្នាំ ២០១៨** ដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** បន្តកិច្ចសហការជាមួយក្រសួងទេសចរណ៍, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, សភាពការណ៍គ្រឿងញៀន, ចំណេះដឹងទូទៅពីគ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមតំបន់ទេសចរណ៍របស់រាជធានី-ខេត្ត គ្រឹះស្ថានសិក្សា និងបណ្តារោងចក្រនានា ។

**១.២.** ត្រៀមចូលរួមផ្តល់កិច្ចសម្ភាសន៍ ក្រោមប្រធានបទស្តីពីលទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ របស់រាជរដ្ឋាភិបាល នៅស្ថានីយទូរទស្សន៍ហង្សមាស ។

**១.៣.** បន្តសហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី. អញ្ជើញតំណាងស្នងការនគរបាលកំពង់ចាម ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងតំណាងស្នងការនគរបាលក្រចេះ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច ក្រោមប្រធានបទ ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ។

**១.៤.** បន្តសហការជាមួយស្ថានីយទូរទស្សន៍បាយ័ន ហង្សមាស និង NICETV ដើម្បីធ្វើការផ្សព្វផ្សាយពីការងារដែលទាក់ទងនឹងបញ្ហាគ្រឿងញៀន។

**១.៥.** បន្តចលនាឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

**១.៦.** បន្តបោះពុម្ពខិត្តប័ណ្ណអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន សម្រាប់ផ្សព្វផ្សាយអប់រំទៅលើក្រុមគោលដៅជាសិស្សានុសិស្ស ។

**១.៧.** បន្តជំរុញនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ធ្វើសកម្មភាពផ្សព្វផ្សាយអប់រំជាមួយវិស័យឯកជន និងក្រុមហ៊ុន ។

### ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើ សមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

**២.១.** បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្ម ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព ។

**២.២.** ជំរុញនិងពង្រឹងសមត្ថភាព គុណភាពនៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្ន សម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**២.៣.** អគ្គលេខាធិការ អ.ជ.ប.គ.ញ. ត្រៀមដឹកនាំប្រតិភូចូលរួមជាអធិបតី និងសហការរៀបចំសិក្ខាសាលាកម្ពុជា-ថៃ ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ពីថ្ងៃទី០៨-១០ខែសីហាឆ្នាំ២០១៨ ។

**២.៤.** បន្តជំរុញការរៀបចំគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាលនិងស្តារនីតិសម្បទា នៅតាម ឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាព សម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

**២.៥.** បន្តដំណើរការសាងសង់មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

**២.៦.** បន្តជំរុញការរៀបចំសេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន ដែលជាទណ្ឌិតនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ ។

**២.៧.** បន្តចលនា និងផ្តល់ការសម្របសម្រួលឱ្យមានការចូលរួមពីវិស័យឯកជន លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**២.៨.** ត្រៀមចុះត្រួតពិនិត្យមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន របស់រដ្ឋ និងឯកជន ។

## ៣. **ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់**

**៣.១.** បន្តកិច្ចសហការជាមួយអង្គការ UNODC ដើម្បីរៀបចំបង្កើតការិយាល័យទំនាក់ទំនង (**BLO**) ថ្មី កម្ពុជា-វៀតណាម ចំនួន ២ នៅច្រកទ្វារព្រំដែនអន្តរជាតិអូយ៉ាដាវ (ខេត្តរតនគិរី) និងច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក (ខេត្តកំពត) ។

**៣.២.** ត្រៀមជួបពិភាក្សាការងារជាមួយសមាជិកដែលពាក់ព័ន្ធអំពីការអនុវត្តគម្រោង PATROL នៅតាមព្រំដែននៃច្រកទ្វារនីមួយៗ ។

**៣.៣.** បន្តបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ស្តីពីគ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) និងតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (e-Learning) ។

**៣.៤.** ជំរុញការបង្កើតក្រុមការងារត្រួតពិនិត្យគ្រឿងញៀន តាមអាកាសយានដ្ឋាន និងកំពង់ផែអន្តរជាតិ ។

## ៤. **ការត្រួតពិនិត្យសារធាតុគីមីផ្សំ**

**៤.១.** បន្តពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធក្នុងការគ្រប់គ្រង ត្រួតពិនិត្យសារជាតុគីមីផ្សំដែលជាវត្ថុធាតុដើម ព្រមទាំងសារជាតុញៀនផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ការបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់ ។

**៤.២.** បន្តសហការជាមយក្រសួងឧស្សាហកម្ម និងសិប្បកម្ម រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមី រោងចក្រ សហគ្រាស ឱ្យមានការយល់ដឹងពីសារជាតុគីមីផ្សំដែលអាចបង្វែរយកទៅផលិតជាគ្រឿងញៀនខុសច្បាប់ ។

**៤.៣.** បន្តសិក្សាស្រាវជ្រាវប្រមូលពត៌មានដែលពាក់ព័ន្ធការប្រើប្រាស់សារជាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

## ៥. **កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន**

**៥.១.** ត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ លើកទី១២ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ថ្ងៃទី០៣-០៦ ខែកញ្ញា ឆ្នា២០១៨ នៅសៀមរាប ។

**៥.២.** បន្តអនុវត្តផែនការសកម្មភាព ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី កម្ពុជា-ថៃ ឆ្នាំ២០១៧-២០១៨ ។

**៥.៣.** បន្តអនុវត្តផែនការសកម្មភាពគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់កម្ពុជា ថៃ ឡាវ រយៈពេល ២ឆ្នាំ (២០១៧ -២០១៨) ។

៥.៤. ត្រៀមទៅចូលរួមកិច្ចប្រជុំត្រីភាគី-ទ្វេភាគី ថ្នាក់រដ្ឋមន្ត្រី កម្ពុជា-ឡាវ-វៀតណាម ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

**៦.១.** ត្រៀមចូលរួមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន។

**៦.២.** ត្រៀមចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន លើកទី៣៩ ស្តីពីបញ្ហាគ្រឿងញៀន ។

**៦.៣.** ត្រៀមចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន លើកទី៦ ស្តីពីបញ្ហាគ្រឿងញៀន ។

**៦.៤.** ត្រៀមធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋាន (AAITF) ។

**៦.៥.** ត្រៀមចូលរួមកិច្ចប្រជុំមន្ត្រីទំនាក់ទំនងប្រឆាំងគ្រឿងញៀនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (ADLOMICO)។

**៦.៦.** បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-កូរ៉េ សំដៅពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន និងគាំទ្រដល់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៦.៧.** បន្តចូលរួមអនុវត្តគម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Coordination Project) ឆ្នាំ២០១៦-២០១៨ ដែលគម្រោងនេះនឹងត្រូវបន្តសម្រាប់រយៈពេល៥ឆ្នាំទៀត (២០១៩-២០២៣) ជាផែនការប្រតិបត្តិការរួមគ្នាត្រួតពិនិត្យគ្រឿងញៀនសុវត្ថិភាពទន្លេមេគង្គ ។

**៦.៨.** បន្តចូលរួមអនុវត្តគម្រោងអនុតំបន់ តំបន់មួយ រួមមាន៖ គម្រោង PATROL, Container Control Program, AirCargo និង e-Learning របស់អង្គការ UNODC Mekong Project របស់សាធារណរដ្ឋកូរ៉េ ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**៧.១.** បន្តណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាពសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

**៧.២.** បន្តការចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ ឆ្នាំ២០១៨។

**៧.៣.** បន្តការរៀបចំខ្លឹមសារនៃសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៧.៤.** បន្តការរៀបចំនីតិវិធីដាក់បញ្ចូលស្លឹករុក្ខជាតិខាត (KHAT) ទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អគ្គលេខាធិការ**

នាយឧត្តមសេនីយ៍ មាស វីរិទ្ធ

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ.
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.

"ដើម្បីជូនជ្រាប"

- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

- ឯកសារ-កាលប្បវត្តិ